ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

ឆ្នាំទី ១០ លេខ ៣

# ព្រឹត្តិបត្រព័ត៌មាន

## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

## សកម្មភាព ការងារ

ECOSOCC

ក ស វ



Work Activities

ប្រចាំខែមីនា ឆ្នាំ២០១៧



# មាតិកា


ល.រ បរិយាយ លេខទំព័រ

I- កិច្ចប្រជុំជំនាញបច្ចេកទេស

- សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ១-២

II- សកម្មភាពការងាររបស់ក្រុមវាយតម្លៃលើផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត( ក្រុម RIA )

- ប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ស្តីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត ៣-៤

III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ ៥-១២

IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី **យឹម ឈុនឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៧ ១៣-១៥

# សេចក្តីព្រាងច្បាប់ស្តីពី
## កិច្ចការពារអ្នកប្រើប្រាស់

កាលពីថ្ងៃទី១៥ ថ្ងៃទី២២ ខែកុម្ភៈ និងថ្ងៃទី២៩ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី មានបើកអង្គប្រជុំជំនាញបច្ចេកទេស ក្រោមអធិបតីភាព លោកជំទាវ **តាល់ ណៃអ៊ីម** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និង ឯកឧត្តម **ឌីម សុខហាក់** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ជាសហប្រធានអង្គប្រជុំ ដើម្បីពិនិត្យពិភាក្សាលើ**សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់** ដោយមានការអញ្ជើញចូលរួមពី សមាជិក និងមន្ត្រីនៃ ក.ស.វ. សមាជិក និងមន្ត្រីនៃក្រុមប្រឹក្សាអ្នកច្បាប់ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី តំណាងអគ្គលេខាធិការរាជរដ្ឋាភិបាល តំណាងខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី **សុខ អាន** មន្ត្រីជំនាញទីស្តីការគណៈរដ្ឋមន្ត្រី និងតំណាងក្រសួងពាណិជ្ជកម្ម។



ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ គឺជាផ្នែកមួយដ៏មានសារៈសំខាន់នៃប្រព័ន្ធច្បាប់នៅលើពិភពលោក ដោយដើរទន្ទឹមគ្នាជាមួយនឹងច្បាប់ស្តីពីការប្រកួតប្រជែង ដែលជាផ្នែកមួយនៃដំណើរការទីផ្សារប្រកបដោយប្រសិទ្ធភាព។ យោងតាមដំណើរការអភិវឌ្ឍយូរអង្វែង តាមគោលការណ៍អាស៊ាន និងអង្គការពាណិជ្ជកម្មពិភពលោក (WTO) ក្រសួងពាណិជ្ជកម្មបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ដើម្បីការពារអ្នកប្រើប្រាស់នៅក្នុងព្រះរាជាណាចក្រកម្ពុជា ពីអំពើ និងសកម្មភាពមិនសុចរិតដែលប្រព្រឹត្តដោយពាណិជ្ជករ និងអ្នកប្រកបមុខរបរវិជ្ជាជីវៈផ្សេងទៀត។

ការបង្កើតច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ត្រូវបានរៀបចំដោយយោង និងផ្អែកលើមូលដ្ឋានមួយចំនួន ដូចជា៖

•មាត្រា៦៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាបានហាមឃាត់ និងផ្តន្ទាទោសជាទម្ងន់ដល់ជនណាដែលនាំចូលផលិតផល លក់ដូរគ្រឿងញៀន ទំនិញក្លែងក្លាយ ទំនិញហួសរយៈពេលប្រើប្រាស់ដែលប៉ះពាល់ដល់សុខភាព និងអាយុជីវិតអ្នកប្រើប្រាស់។

•ក្នុងនាមជាសមាជិកនៃអង្គការសហប្រជាជាតិ( UN ) អង្គការពាណិជ្ជកម្មពិភពលោក( WTO ) និងអង្គការអាស៊ាន( ASEAN ) ប្រទេសកម្ពុជាត្រូវគោរព និងអនុវត្តតាមគោលការណ៍នៃអង្គការទាំងនេះ ដែលតម្រូវឲ្យមានច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់។

•កិច្ចការពារអ្នកប្រើប្រាស់គឺជា ផ្នែកមួយនៃទំនើបកម្ម សក្តានុពល ប្រសិទ្ធភាព និងភាពស្មើគ្នាក្នុងការប្រកួតប្រជែងលើទីផ្សារ។ ការកើនឡើងនៃការធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការធ្វើពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិច និងការប្រើយុទ្ធសាស្ត្រ ដើម្បីធ្វើពាណិជ្ជកម្មថ្មីផ្សេងទៀត ដែលកើតចេញពីសកលភាវូបនីយកម្ម និងភាពរីកចម្រើននៃបច្ចេកវិទ្យា បានតម្រូវឲ្យរដ្ឋាភិបាលស្វែងរកមធ្យោបាយថ្មីដើម្បីការពារ និងលើកទឹកចិត្តចំពោះអ្នកប្រើប្រាស់។ ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់និងផ្តល់ជូនអ្នកប្រើប្រាស់នូវព័ត៌មានគ្រប់គ្រាន់ ដើម្បីធ្វើការជ្រើសរើសផលិតផលឲ្យបានសមស្របតាមតម្រូវការ ការតបស្នងដ៏មានប្រសិទ្ធភាព និងការទទួលបាននូវផលិតផល និងសេវាដែលមានបទដ្ឋានត្រឹមត្រូវ និងសុវត្ថិភាពខ្ពស់។

- ផែនការសកម្មភាពរបស់គណៈកម្មាធិការអាស៊ានស្តីពីការការពារអ្នកប្រើប្រាស់។

- កម្មវិធីការងារ និងផែនការសកម្មភាពរបស់ក្រសួងពាណិជ្ជកម្មដែលត្រូវដាក់បញ្ចូលក្នុងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

សេចក្តីព្រាងច្បាប់នេះមានសារៈប្រយោជន៍ ដូចតទៅ៖

១- ការពារសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់

២- គាំទ្រទីផ្សារឲ្យមានការប្រកួតប្រជែងទាំងតម្លៃ និងគុណភាពទំនិញ និងសេវា

៣- បង្កើតបរិយាកាសនៃការធ្វើពាណិជ្ជកម្ម ដែលសិទ្ធិ និងផលប្រយោជន៍របស់អ្នកប្រើប្រាស់ត្រូវបានការពារ ហើយធ្វើឲ្យពាណិជ្ជកម្មនោះមានការប្រកួតប្រជែងដោយស្មើភាព ដោយអ្នកប្រើប្រាស់ និងពាណិជ្ជករធ្វើសកម្មភាពជាមួយគ្នាប្រកបដោយទំនុកចិត្ត[១]។

អង្គប្រជុំបានពិនិត្យពិភាក្សាលើសេចក្តីព្រាងច្បាប់នេះ ហើយបានសម្រេចកែសម្រួលទម្រង់ ខ្លឹមសារពាក្យពេចន៍ និងឃ្លាប្រយោគផ្សេងទៀត បានមួយចំនួន នឹងបន្តពិនិត្យពិភាក្សាទៀត ដើម្បីធ្វើឲ្យសេចក្តីព្រាងច្បាប់នេះកាន់តែល្អ៕

---

(១) អត្ថបទនេះដកស្រង់ពីសេចក្តីព្រាងសេចក្តីថ្លែងហេតុរបស់សេចក្តីថ្លែងហេតុរបស់សេចក្តីព្រាងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ។

# ប្រជុំប្រចាំត្រីមាសទី១ឆ្នាំ២០១៧
## ស្ដីពីការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត



នៅព្រឹកថ្ងៃសុក្រ ទី៣១ ខែមីនា ឆ្នាំ២០១៧ នៅទីស្ដីការគណៈរដ្ឋមន្ត្រី ឯកឧត្តម **ឃឹម ណុលសន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) និងជាប្រធានក្រុមប្រតិបត្តិលិខិតបទដ្ឋានគតិយុត្ត (RET) បានដឹកនាំប្រជុំបូកសរុបការងារវាយតម្លៃលើផលប៉ះពាល់ នៃលិខិតបទដ្ឋានគតិយុត្ត (RIA) ប្រចាំត្រីមាសទី១ឆ្នាំ២០១៧ ដើម្បីពិនិត្យវាយតម្លៃលើការងារអនុវត្តកន្លងមក និងលើកផែនការសកម្មភាពសម្រាប់បន្តក្នុងឆ្នាំ២០១៧ និងទិសដៅឆ្នាំ២០១៨។

អ្នកចូលរួមមានចំនួនប្រមាណ៩០រូប ក្នុងនោះមានក្រុមRET និងក្រុមRIAមកពីក្រសួង ស្ថាប័នចំនួន ១៧៖ ក្រសួងពាណិជ្ជកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងបរិស្ថាន ក្រសួងទេសចរណ៍ ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់និងនេសាទ ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងសុខាភិបាល ក្រសួងប្រៃសណីយនិងទូរគមនាគមន៍ ក្រសួងសាធារណៈការ និងដឹកជញ្ជូន ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ក្រសួងយុត្តិធម៌ ក្រសួងការពារជាតិ រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

ជាកិច្ចចាប់ផ្តើម ឯកឧត្តម **យឹម ណុលសន** ប្រធានអង្គប្រជុំបានស្វាគមន៍ និងវាយតម្លៃខ្ពស់ចំពោះការអនុវត្តRIA របស់ក្រសួង ស្ថាប័ន។

តំណាងក្រុមRIAមកពីក្រសួង ស្ថាប័នចំនួន១៧ បានរាយការណ៍ពីវឌ្ឍនភាព បញ្ហាប្រឈមក្នុងការអនុវត្តRIA កន្លងមក និងលើកទិសដៅសម្រាប់ការអនុវត្តបន្ត។

ការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត(RIA) គឺជាទម្លាប់អនុវត្តល្អសម្រាប់ដំណើរការរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្ត ដែលផ្តល់ផលចំណេញច្រើន ហើយមានប្រទេសអភិវឌ្ឍជាច្រើនដែលជាសមាជិកនៃ OECD (អង្គការអភិវឌ្ឍសេដ្ឋកិច្ចនិងសហប្រតិបត្តិការ) និងប្រទេសASEAN បានទទួលស្គាល់យ៉ាងទូលំទូលាយថា៖

- លិខិតបទដ្ឋានមានគុណភាពខ្ពស់ ដែលមានអភិបាលកិច្ចល្អ និង ការអភិវឌ្ឍសេដ្ឋកិច្ច
- អ្នកធ្វើសេចក្តីសម្រេចអាចធ្វើការសម្រេចបញ្ញត្តិកម្មប្រកបទៅដោយទិន្នន័យផ្អែកលើការអនុវត្តជាក់ស្តែង
- បង្កើនតម្លាភាព និងកសាងជំនឿទុកចិត្តដល់សាធារណៈជន ដោយសារមានគោលការណ៍ណែនាំច្បាស់លាស់សម្រាប់កិច្ចពិគ្រោះយោបល់ជាមួយភាគីពាក់ព័ន្ធ;
- ជួយកាត់បន្ថយបន្ទុកចំណាយរបស់រាជរដ្ឋាភិបាលលើការអនុវត្ត និងបន្ទុកចំណាយប្រតិបត្តិការរបស់ធុរកិច្ច

អភិបាលកិច្ចល្អ គឺជាចំណុចកណ្តាលនៃរបៀបវារៈរបស់រាជរដ្ឋាភិបាលដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណ។ ដំណើរការ RIA នឹងកាត់បន្ថយការិយាធិបតេយ្យ និងភាពច្រើនហួស/ភាពជាន់គ្នានៃលិខិតបទដ្ឋានគតិយុត្ត៕



# III- កិច្ចប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧



របាយការណ៍ស្តីពីស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា **ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧** នេះ ជាលទ្ធផលនៃកិច្ចប្រជុំទូលាយក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌(ECOSOCC) នៅថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៧ ក្រោមអធិបតីភាព ឯកឧត្តម **យឹម ណុលឡា** ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ECOSOCC) ដោយមានការអញ្ជើញចូលរួមពី អនុប្រធាន សមាជិក សមាជិកា អគ្គលេខាធិការ អគ្គលេខាធិការរង ក.ស.វ. និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធ។

## ១) ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់

➡ នាខែកុម្ភៈឆ្នាំ២០១៧សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់កើនឡើង០,១% ធៀបនឹងខែមុន និងកើនឡើង៤,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន (រយៈពេល១២ខែ)។

តារាង១.១. បម្រែបម្រួលថ្លៃធៀបនឹងខែដូចគ្នាឆ្នាំមុនសម្រាប់ក្រុមទំនិញនិងមុខទំនិញមួយចំនួន

| *ក្រុមទំនិញ:* | | *មុខទំនិញ:* | |
|---|---|---|---|
| ម្ហូបអាហារ: | +៥,៧% | បន្លែ: | +១៣,២% |
| សំលៀកបំពាក់ និងស្បែកជើង: | +៣,៨% | ត្រីស្រស់: | +១០,៧% |
| ការដឹកជញ្ជូន: | +៣,៧% | ប្រេងសាំង: | +៦,៤% |
| ភេសជ្ជៈមានជាតិស្រវឹង និងថ្នាំជក់: | +៣,៥% | សាច់មាន់: | +៦,០% |
| ភោជនីយដ្ឋាន: | +៣,៥% | សាច់គោ | +៤,៤% |
| ទំនិញ និងសេវាកម្មផ្សេងៗ | +២,៦% | ប្រេងម៉ាស៊ូត: | +៤,១% |
| ការកំសាន្ត និងវប្បធម៌: | +២,៤% | ផ្លែឈើ: | +៣,៩% |
| គ្រឿងសង្ហារឹមនិងសម្ភារៈប្រើប្រាស់: | +២,២% | សាច់ជ្រូក: | +៣,២% |
| សុខាភិបាល: | +២,០% | | |

តារាង១.២. បម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ ២០១៥–២០១៧

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា P | មេសា P | ឧសភា P | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០១៧ | ដូចគ្នាឆ្នាំមុន | ៤,៤% | ៤,០% | ៤,០% | ៤,០% | ៣,៩% | | | | | | | | |
| | មុន | ០,៣% | ០,១% | -០,២% | ១,៤% | ០,៤% | | | | | | | | |
| ២០១៦ | ដូចគ្នាឆ្នាំមុន | ៣% | ២,៣% | ២,០% | ២,៨% | ៣,១% | ៣,៣% | ៣,០% | ២,៩% | ៣,០% | ៣,៤% | ៣,៦% | ៣,៩% | ៣% |
| | មុន | -០,២% | ០,៤% | -០,២% | ១,៤% | ០,៥% | ០,២% | ០,៣% | ០,២% | ០,៣% | ០,៤% | ០ | ០,៤% | |
| ២០១៥ | ដូចគ្នាឆ្នាំមុន | ០,៤% | ១,៦% | ១,១% | ១,៣% | ១,០% | ០,៧% | ០,៨% | ០,៨% | ០,៩% | ១,៣% | ១,៩% | ២,៨% | ១,២% |
| | មុន | -០,៤% | ១,២% | ០,១% | ០,៧% | ០,១% | ០,២% | ០,៦% | ០,៣% | ០,២% | ០% | -០,២% | ០,២% | |

P: តួលេខខែ មីនា មេសា និងឧសភា ឆ្នាំ២០១៧ ជាតួលេខព្យាករ (តាមវិធីសាស្រ្ត DECOMPOSITION)

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។
* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរ និងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឲ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ )Excel) សញ្ញាក្បៀសតាងឲ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។

ក្រាហ្វ ១.១. ចលនានិងបម្រែបម្រួលសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់




តារាង១.៣. អត្រាប្តូរប្រាក់

| *ប្រភេទ* | កុម្ភៈ ២០១៧ | មករា២០១៧ | កុម្ភៈ ២០១៦ | *ប្រភេទ* | កុម្ភៈ ២០១៧ | មករា២០១៧ | កុម្ភៈ ២០១៦ |
|---|---|---|---|---|---|---|---|
| **៛/ដុល្លារ** | ៤០០៤៛/១$ | ៤០៣៥៛/១$ | ៤០០៨៛/១$ | **បាត/ដុល្លារ** | ៣៤,៨៥បាត/១$ | ៣៥,២០បាត/១$ | ៣៥,៧៣បាត/១$ |
| **៛/បាត** | ១១៥៛/១បាត | ១១៥៛/១បាត | ១១២៛/១បាត | **ដុង/ដុល្លារ** | ២២៧៧៧ដុង/១$ | ២២៥៩០ដុង/១$ | ២២២៩៣ដុង/១$ |
| **៛/ដុង** | ០,១៧៦៛/១ដុង | ០,១៧៩៛/១ដុង | ០,១៨០៛/១ដុង | | | | |

## ២) ស្ថានភាពថវិកាជាតិ

➡យោងតាមស្ថិតិរបស់រតនាគារជាតិ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ និងអគ្គនាយកដ្ឋានពន្ធដារក្នុងខែកុម្ភៈ ឆ្នាំ ២០១៧ ថវិកាជាតិមានស្ថានភាពដូចខាងក្រោម:

**២.១. ចំណូលថវិកាជាតិ** : អនុវត្តបាន១៤២២,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៥៥,៦ លានដុល្លារ ( *មធ្យមប្រចាំខែ ៩៣% នៃផែនការ*) ក្នុងនោះចំណូលចរន្ត ចំនួន១៤២២,៥ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ៣៥៥,៦ លានដុល្លារ ( *មធ្យមប្រចាំខែ ៩៦% នៃផែនការ*) និងមិនមានចំណូលមូលធនទេ(តាមតួលេខ រតនាគារជាតិ)។

➢បើធៀបនឹងខែមុន ចំណូលថវិកាជាតិកើនឡើង៣៥,២% និងកើនឡើង៣៥,០% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢នៅក្នុងចំណូលចរន្ត:

✓ចំណូលសារពើពន្ធមានចំនួន ១៣០៧,៨ប៊ីលានរៀល កើនឡើង២៩,៨%ធៀបនឹងខែមុន និងកើនឡើង ៣៦,១% ធៀបនឹងខែដូចគ្នាឆ្នាំមុន (តាមតួលេខ រតនាគារជាតិ)។

ក្រាហ្វ ២.១. ចំណូលថវិកាជាតិ ឆ្នាំ ២០១៥ –២០១៧

(ប៊ីលានរៀល)




✓ចំណូលមិនមែនសារពើពន្ធ មានចំនួន១១៤,៧ប៊ីលានរៀល កើនឡើង១៥៦,០% ធៀបនឹងខែមុន និងកើនឡើង៣៦,៤% ធៀបនឹងខែដូចគ្នាឆ្នាំមុន(តាមតួលេខ រតនាគារជាតិ)។

**តារាង២.១. មុខចំណូលមួយចំនួនក្នុងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ**

| **ចំណូលសារពើពន្ធ** (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | | **ចំណូលមិនមែនសារពើពន្ធ** (តាមតួលេខ រតនាគារជាតិ) (ក្នុងវង់ក្រចក:បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន) | |
|---|---|---|---|
| ➢ ពន្ធ និងអាករគយ: +៩,៧% (អគ្គនាយកដ្ឋានគយ និងរដ្ឋាករ) | (+៧,៨%) | ➢កាស៊ីណូ : +១២៨,០% | (+៥៩,២%) |
| | | ➢អាជ្ញាបណ្ណក្នុងស្រុក : +៥៩៥,៨% | (+៦៤,៩%) |
| ➢ ចំណូលពន្ធដារ: -៥៧,៣% (អគ្គនាយកដ្ឋានពន្ធដារ) | (+១០,០%) | ➢ នេសាទ:-៩២,៩% | (-៦៦,២%) |
| | | ➢សម្បទានរ៉ែ: -៣០,២% | (+២៤,៨%) |
| | | ➢ អាកាសចរណ៍ស៊ីវិល: +១០៩៦,៣% | (+៧,១%) |
| | | ➢ផលទុននៃសកម្មភាពទេសចរណ៍: កើនគំហុក | (កើនគំហុក) |
| | | ➢អាករស្ថានទូត(លិខិតឆ្លងដែននិងទិដ្ឋាការ): +១១,៤% | (-៤,៧%) |
| | | ➢ការត្រួតពិនិត្យគុណភាពផលិតផល: +៤៥៨,៤% | (-២៣,០%) |

**២.២. ចំណាយថវិកាជាតិ** :អនុវត្តបាន ៨៨៧,៩ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ២២២ លានដុល្លារ( *មធ្យមប្រចាំខែ ៥២% នៃផែនការ*) ក្នុងនោះ ចំណាយចរន្ត ចំនួន ៨៤៥,៥ប៊ីលានរៀល ( *មធ្យមប្រចាំខែ ៥៩% នៃផែនការ*) និងចំណាយមូលធនមានចំនួន៤២,៤ប៊ីលានរៀល( តាមតួលេខ រតនាគារជាតិ )។

➢ចំណាយថវិកាជាតិកើនឡើង៨៤,១% ធៀបនឹងខែមុននិងកើនឡើង១៨,៥% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះចំណាយចរន្តកើនឡើង៨៩,៨% ធៀបនឹងខែមុននិងកើនឡើង៤៨,៨% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

**២.៣. សមតុល្យថវិកាជាតិ** : ថវិកាជាតិនាខែនេះមានអតិរេកចំនួន ៥៣៤,៦ប៊ីលានរៀល គិតជាដុល្លារអាមេរិកស្មើ ១៣៣,៦៥ លានដុល្លារ( តួលេខរតនាគារជាតិ )។

ក្រាហ្វ២.២. ចំណាយថវិកាជាតិ ឆ្នាំ ២០១៥–២០១៧ (ប៊ីលានរៀល)




## ៣) ស្ថានភាពរូបិយវត្ថុនិងអត្រាការប្រាក់

➡ស្ថានភាពរូបិយវត្ថុ ក្នុងខែកុម្ភៈឆ្នាំ២០១៧មានលក្ខណៈដូចខាងក្រោម:

➢រូបិយវត្ថុ$M_2$ មានចំនួន៥៩៥៧២ប៊ីលានរៀល កើនឡើង១,២% ធៀបនឹងខែមុន និងកើនឡើង១៨,៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ **ការកើនឡើង $M_2$** ក្នុងខែនេះ ជារួម បណ្ដាលមកពីការកើនឡើងនៃរូបិយវត្ថុក្រៅធនាគារ១,៧% ប្រាក់បញ្ញើចរន្ត ៣,១% និងប្រាក់បញ្ញើជារូបិយបណ្ណ១,៣%។

ក្រាហ្វ៣.១. សមាសធាតុរូបិយវត្ថុខែកុម្ភៈឆ្នាំ២០១៧



➤ក្នុងខែនេះ ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារមានចំនួន១៦,៦% និងប្រាក់បញ្ញើជារូបិយបណ្ណមានចំនួន ៨៣,៤% នៃរូបិយវត្ថុ$M_2$។

តារាង៣.១. សមាមាត្រចំនួនប្រាក់រៀល នៅក្នុងរូបិយវត្ថុ $M_2$ឆ្នាំ២០១៧

| ប្រាក់រៀលសរុបនៅក្នុងនិងក្រៅធនាគារ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ១៦,៧% | ១៦,៦% | | | | | | | | | | |
| ប្រាក់រៀលក្រៅធនាគារ | ១១,៣% | ១១,៤% | | | | | | | | | | |

ក្រាហ្វ៣.២.បម្រែបម្រួលសមាសធាតុរូបិយវត្ថុខែកុម្ភៈ២០១៧: ក្នុងវង់ក្រចកជាបម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន




➤<u>**ទុនបម្រុងជារូបិយបណ្ណបរទេសសុទ្ធ**</u> <u>(មិនទាន់ទទួលបានតួលេខ)</u>

➤ ***ប្រាក់បញ្ញើរបស់ធនាគារពាណិជ្ជនៅធនាគារជាតិ*** ក្នុងខែនេះមានចំនួន ២០៨១៣ ប៊ីលានរៀល កើនឡើង ១,២%ធៀបនឹងខែមុន និងកើនឡើង៣២,៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៣.២.ការផ្តល់ឥណទាននិងអត្រាការប្រាក់ប្រចាំឆ្នាំ

| *ផ្តល់ដោយ* | *កុម្ភៈ២០១៧* | *មករា២០១៧* | *កុម្ភៈ២០១៦* |
|---|---|---|---|
| ឥណទានផ្តល់ដោយធនាគារពាណិជ្ជ(ប៊ីលានរៀល) | ៥៨២៤៤ | ៥៨២២៧ | ៥០៦០៥ |
| ក្នុងនោះ ជារៀល | | | ៦៤២ |
| ឥណទានផ្តល់ដោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ(ប៊ីលានរៀល) | | ១៣០២៧ | ១២៧៣៧ |
| អត្រាការប្រាក់បញ្ញើជារៀលនៅធនាគារពាណិជ្ជ | | ៦,៨៥% | ៦,៥៣% |
| អត្រាការប្រាក់កម្ចីជារៀលនៅធនាគារពាណិជ្ជ | | ១៦,២៤% | ១៦,៣៥% |
| អត្រាការប្រាក់បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | | ៤,៤៤% | ៤,៤៥% |
| អត្រាការប្រាក់កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | | ១១,៩២% | ១១,៤៥% |
| អត្រាការប្រាក់កម្ចីជារៀលនៅហត្ថកសិករ | | ២៣,៤% | ៣១,២% |
| អត្រាការប្រាក់កម្ចីជារៀលនៅអម្រឹត | | ២៨,៨% | ២៩,៤% |
| អត្រាការប្រាក់កម្ចីជារៀលនៅប្រាសាក់ | | ២២,៨% | ២២,៨% |

## ៤)ស្ថានភាព កសិកម្ម ឧស្សាហកម្ម សេវាកម្ម និងទេសចរណ៍

➡ក្នុងខែកុម្ភៈឆ្នាំ២០១៧ ស្ថានភាពផលិតកម្មមានលក្ខណៈដូចខាងក្រោម:

➤**កសិកម្ម**:

✓នេសាទសម្រេចបាន ៥០,៤ពាន់តោន ថយចុះ៦% ធៀបនឹងខែមុន ប៉ុន្តែ កើនឡើង ៩% ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**រ៉ែ និងថាមពល**:

✓អគ្គិសនីសរុបផ្គត់ផ្គង់ដោយអគ្គិសនីកម្ពុជាមានចំនួន ៥៧១,៧៦GWHមានការថយចុះ០%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង១៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះផ្គត់ផ្គង់ដោយវារីអគ្គិសនីមានចំនួន៤០,៨៧GWHមានការកើនឡើង០%ធៀបនឹងខែមុន និងកើនឡើង៣%ធៀបនឹងខែដូចគ្នាឆ្នាំមុន អគ្គីសនីផ្គត់ផ្គង់ដោយធ្យូងថ្មមានចំនួន៣៥៤,៤២GWHមានការថយចុះ១%ធៀបនឹងខែមុន ប៉ុន្តែមានការកើនឡើង៣១%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

➢**ឧស្សាហកម្ម**:

✓ផលិតកម្មវាយនភណ្ឌនិងស្បែកជើងមានចំនួន ៥៤៨,២លានដុល្លារមានការកើនឡើង៤%ធៀបនឹងខែមុន និងកើនឡើង៩%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៤.១. ការចុះបញ្ជីរោងចក្រ និងឧស្សាហកម្មធុនតូច និងសិប្បកម្ម នៅក្រសួងឧស្សាហកម្ម

| ប្រភេទ | ចំនួន—កុម្ភៈ២០១៧ | ចំនួន—មករា២០១៧ | ចំនួន—កុម្ភៈ២០១៦ |
|---|---|---|---|
| ▪រោងចក្រថ្មីដែលបានចុះបញ្ជី | ៤ | ៤ | ១២ |
| ▪ ចំនួនរោងចក្រសរុបដែលមានក្នុងបញ្ជី | ១៥៨៥ | ១៥៨៣ | ១៤៧៦ |
| ▪ ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ២១ | ១៤ | ៣ |
| ▪ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បន្ត) | ៣៤ | ២០ | ១៥ |

➢**សំណង់** (ការអនុញ្ញាត):

✓សំណង់អនុញ្ញាតឲ្យសាងសង់មានចំនួន ៨១៨ពាន់ម$^2$កើនឡើង១៥២%ធៀបនឹងខែមុន ប៉ុន្តែថយចុះ៦% ធៀបនឹងខែដូចគ្នាឆ្នាំមុន។ បើគិតជាសាច់ប្រាក់ស្មើនឹង៥៧២លានដុល្លារកើនឡើង២៦៦%ធៀបនឹងខែមុន និងកើនឡើង១២%បើធៀបនឹងខែដូចគ្នាឆ្នាំមុន។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

តារាង៤.២. សំណង់អនុញ្ញាតតាមប្រភេទផ្សេងៗ

| ប្រភេទ | ពាន់ម$^2$—កុម្ភៈ២០១៧ | ពាន់ម$^2$—មករា២០១៧ | ពាន់ម$^2$—កុម្ភៈ២០១៦ |
|---|---|---|---|
| ▪ លំនៅឋាន | ៤៩៤,៤ | ២០៩,២ | ៦១៣,៨ |
| ▪ ឧស្សាហកម្ម | ២០៨,៨ | ១៥,០ | ១៤២,៥ |
| ▪ពាណិជ្ជកម្ម | ១៧,២ | ៧១,៧ | ១០៣,១ |
| ▪ ទេសចរណ៍ | ៩៦,៩ | ២៤,៣ | ៤,៥ |
| ▪ផ្សេងៗ | ០,០ | ០,០ | ១,៣ |
| អនុញ្ញាតសរុប | ៨១៨ | ៣២៥ | ៨៧២,១ |

✓ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមនាខែនេះគឺ លំនៅដ្ឋាន ៦០,៤% និងឧស្សាហកម្ម ២៥,៥% នៃផ្ទៃក្រឡាសរុប។

➢**ការងារ**

តារាង៤.៣. ការស្វែងរកការងារនិងទទួលបានការងារ

| ប្រភេទ | នាក់—កុម្ភៈ ២០១៧ | នាក់—មករា ២០១៧ | នាក់—កុម្ភៈ ២០១៦ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារ (ទីភ្នាក់ងារជាតិមុខរបបនិងការងារ) | ២២៩៣ | ១៦៦១ | ៤៤១ |
| អ្នកទទួលបានការងារតាមរយៈក្រសួងការងារ និងក្រុមហ៊ុន | ១២០០៣ | ២៤៩១០ | ១៣៩៨៧ |
| អ្នកទទួលបានការងារក្នុងប្រទេស | ៩៣៣១ | ២៣២០០ | ១១២៣៤ |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៦៧២ | ១៧១០ | ២៣៥៣ |

## ➢វិនិយោគ

តារាង៤.៤.គម្រោងវិនិយោគអនុញ្ញាតដោយគ.វ.ក./ក.អ.ក. (ថ្មីនិងពង្រីក)

| ប្រភេទ | កុម្ភៈ២០១៧ | មករា២០១៧ | កុម្ភៈ២០១៦ |
|---|---|---|---|
| អនុញ្ញាតសរុប (លានដុល្លារ) | ៤២០ | ៤៣ | ៧៩៨,៩ |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៧០ | ៨ | ៣៨,៣ |
| វិស័យឧស្សាហកម្ម (ក្នុងវង់ក្រចកជាតួលេខនៃតំបន់សេដ្ឋកិច្ចពិសេស) | ៣៤៩ (២៦៣) | ២៧,២ (០,៨) | ៤៧,៧ (១,៦) |
| វិស័យទេសចរណ៍ | ០ | ៣,៦ | ៥៧៣ |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ០ | ៤,២ | ១៤០ |
| ចំនួនគម្រោង ថ្មីនិងពង្រីក (ចំនួន) | ១៨ | ១០ | ២៨ |
| បង្កើតការងារ (ពាន់នាក់) | ២៨ | ៣,៩ | ៣,៩ |

## ➢សេវាកម្ម

តារាង៤.៥.ការចុះបញ្ជីនិងលុបចេញពីបញ្ជី នៅក្រសួងពាណិជ្ជកម្ម

| ប្រភេទ | ចំនួន — កុម្ភៈ២០១៧ | ចំនួន—មករា២០១៦ | ចំនួន—កុម្ភៈ២០១៦ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | | ៣៤១ | ២១២ |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | | ១ | ២ |
| ក្រុមហ៊ុនដែលបានចុះបញ្ជីបង់ពន្ធដារតាមរបបពិត | | ៥២៦ | |

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប៥កំពង់ផែ) មានចំនួន៦៧៥,៤ពាន់តោន ថយចុះ២៣% ធៀបនឹងខែមុន និង ថយចុះ៣% ធៀបនឹងខែដូចគ្នាឆ្នាំមុនក្នុងនោះៈ

តារាង៤.៦.ទំនិញឆ្លងកាត់កំពង់ផែផ្សេងៗ (ក្នុងវង់ក្រចកៈ បម្រែបម្រួលធៀបនឹងខែដូចគ្នាឆ្នាំមុន)

| | | | |
|---|---|---|---|
| ▪ កំពង់ផែភ្នំពេញៈ-២% | (+២%) | ▪ កំពង់ផែស្រែអំបិល និងកោះកុងៈ-៤៨% | (-៩១%) |
| ▪ កំពង់ផែកំពង់សោមៈ-៣២% | (+៤%) | ▪ កំពង់ផែឧកញ៉ាម៉ុងៈ -៥% | (+៣%) |

## ➢ប្រៃសណីយ៍និងទូរគមនាគមន៍

| ប្រភេទ | ចំនួន | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១៥,៤ | -៣% | ២០% |
| ក្នុងនោះទទួល | ២,៣ | -៥% | ៨% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ១១៣,២ | -៩% | -១០% |
| ក្នុងនោះទទួល | ៤៦,៣ | -២២% | -៤% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ២៣៩១,២ | -៦% | -១៦% |
| ក្នុងនោះហៅចូល | ៦៩៦ | -៧% | -១៦% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ១០៧២៦ | ៣% | -១០% |
| ក្នុងនោះហៅចូល | ១០៦៦២,៩ | ៣% | -១០% |

**➢ការធ្វើដំណើរតាមផ្លូវអាកាសនិងទេសចរណ៍**

តារាង៤.៧.អ្នកដំណើរតាមផ្លូវអាកាសនិងទេសចរណ៍

| ប្រភេទ | ចំនួន( ពាន់នាក់ ) | %Δ ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ២៨,៦ | ៣៩% | ៣០% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ៤៨,០ | -៤% | ០% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ៦៨៦,៣ | -៧% | ១៦% |
| ចំនួនទេសចរជាតិចេញក្រៅប្រទេស | ១២១,៩ | -១% | ៥% |
| ចំនួនទេសចរអន្តរជាតិមកព្រះរាជាណាចក្រកម្ពុជា | ៤៩៣,៣ | -៧% | ១០% |
| ✓ តាមផ្លូវអាកាស | ៣០១,៣ | -៨% | ១៣% |
| ✓ តាមផ្លូវគោក និងទឹក | ១៩២ | -៦% | ៦% |

## ៥) ស្ថានភាពជញ្ជូនពាណិជ្ជកម្ម

➡ពីប្រភពអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ការនាំចូលនាខែកុម្ភៈ ឆ្នាំ២០១៧ មានចំនួន ៤២៤២,៦ប៊ីលានរៀល (ស្មើនឹង១០៦០,៦លានដុល្លារ ស.រ.អា.)ថយចុះ៤,៣%ធៀបនឹងខែមុន ប៉ុន្តែកើនឡើង៥,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន ក្នុងនោះ :

តារាង៥.១.បម្រែបម្រួលនៃការនាំចូលមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δ□ធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ប្រេងសាំង | -២,៧% | -២,១% | រថយន្តសរុប (ប៊ី.ល.រ) | -៣១,៧% | -១៨,២% |
| ប្រេងម៉ាស៊ូត | -៦,២% | +៧,២% | រថយន្តសរុប (គ្រឿង) | +២៥,៦% | -១២,១% |
| ឧស្ម័ន | -២,៦% | +៧,៦% | ត្រាក់ទ័រនិងគោយន្ត(គ្រឿង) | -១៧,៥% | -៥០,៣% |
| អគ្គិសនីនាំចូល | -១% | +០% | ម៉ូតូ (គ្រឿង) | +២០,៦% | -១៦,៧% |
| ដែកសំណង់ | -២០,៧% | +១៤,១% | អង្ករ | -២២,៧% | -៩០,២% |
| ស៊ីម៉ង់ត៍ | +២៥,៣% | +១២,៥% | ផ្លែឈើនិងបន្លែ | -២៧,៥% | -១២,៥% |
| គ្រឿងអេឡិចត្រូនិក | -៤១,៣% | -២៥,៣% | ជីនិងថ្នាំកសិកម្ម | +២៥,១% | +២៥០,៩% |
| | | | នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | -៣៣,១% | -៨,២% |

➡ **ការនាំចេញ** ខែកុម្ភៈឆ្នាំ២០១៧ មានចំនួន**៣៣៣២,៦**ប៊ីលានរៀល ស្មើនឹង**៨៣៣,២**លានដុល្លារ ស.រ.អា. (**៧៨,៥**% នៃការនាំចូល)កើនឡើង១,៩%ធៀបនឹងខែមុន និងកើនឡើង៩,២%ធៀបនឹងខែដូចគ្នាឆ្នាំមុន។

តារាង៥.២.បម្រែបម្រួលនៃការនាំចេញមុខទំនិញមួយចំនួន

| ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន | ទំនិញ | %Δធៀបនឹងខែមុន | %Δធៀបនឹងខែដូចគ្នាឆ្នាំមុន |
|---|---|---|---|---|---|
| ផលិតផលឈើកែច្នៃ | +៩,៦% | +៨៧,៨% | ផលិតផលនេសាទ | +៤៨,២% | -៤,៣% |
| វាយនភណ្ឌនិងស្បែកជើង | +០,៤% | +៤,៨% | កៅស៊ូ | -៣០,៣% | +៦៩,២% |
| អង្ករ | +១២,១% | +៩,៦% | | | |

## ៦) បម្រែបម្រួលគួរឲ្យចាប់អារម្មណ៍

ក្នុងខែកុម្ភៈឆ្នាំ២០១៧នេះ សូចនាករសេដ្ឋកិច្ច សង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជាបង្ហាញបម្រែបម្រួលគួរឲ្យចាប់អារម្មណ៍ដូចក្នុងតារាងខាងក្រោម។

តារាង៦.១. បម្រែមប្រួលគួរឲ្យចាប់អារម្មណ៍ នៃសូចនាករមួយចំនួន

| ល.រ | សូចនាករ | ធៀបនឹងខែមុន | ធៀបនឹងខែដូចគ្នាឆ្នាំមុន | កំណត់សម្គាល់ |
|---|---|---|---|---|
| ១ | ថ្លៃបន្លែ | -0,៦% | +១៣,២% | — |
| ២ | ថ្លៃត្រីស្រស់ | +0,៥% | +១0,៧% | — |
| ៣ | ថ្លៃប្រេងសាំង | +១,៨% | +៦,៤% | — |
| ៤ | អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារនិងក្រុមហ៊ុន ក្នុងប្រទេស | -៦0% | -១៧% | — |

## ៧) សេចក្តីសន្និដ្ឋាន

១) ថ្លៃទំនិញប្រើប្រាស់ក្នុងឆ្នាំ២០១៧ មាននិន្នាការឡើងខ្ពស់ ដែលជារួមបណ្តាលមកពីក្រុមម្ហូបអាហារ ដូចជាបន្លែ ត្រី និងសាច់ ។ ការឡើងថ្លៃខ្ពស់នៃម្ហូបអាហារ ប៉ះពាល់ខ្លាំងលើប្រជាពលរដ្ឋមួយចំនួនធំ ដែលមានជីវភាពក្រីក្រ និងមធ្យម ដែលចាយជាចម្បងលើ ម្ហូបអាហារ ការធ្វើដំណើរ សេវាសុខភាព និងផ្ទះសម្បែង។

២) ទន្ទឹមនឹងបញ្ហាឱនភាពនៃការផ្គត់ផ្គង់ម្ហូបអាហារក្នុងស្រុក ដូចជាការដាំបន្លែ និងចិញ្ចឹមសត្វ បញ្ហាធ្ងន់ធ្ងរមួយទៀតគឺ សុវត្ថិភាពម្ហូបអាហារ ដែលត្រូវបានលើកមកពិភាក្សាញឹកញាប់ក្នុងកិច្ចប្រជុំវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌កម្ពុជា។ ម្ហូបអាហារដែលបង្កគ្រោះថ្នាក់ដល់សុខភាព ដោយមូលហេតុការប្រើប្រាស់សារធាតុគីមីក្តី ដូចជា សារធាតុរក្សាភាពស្រស់ អ័រម៉ូន អង់ទីយ៉ូទិក ឬក៏បញ្ហាកង្វះអនាម័យក្តី ទាមទារឲ្យមានការយកវិធានការគ្រប់គ្រងត្រួតពិនិត្យឲ្យមានប្រសិទ្ធភាព។ អង្គប្រជុំយល់ឃើញថា គួរមានស្ថាប័នរួមមួយដែលទទួលខុសត្រូវលើការគ្រប់គ្រង និងសុវត្ថិភាពម្ហូបអាហារ បំពាក់ទៅដោយមន្ទីរពិសោធន៍ និងឧបករណ៍ទំនើប សម្រាប់ត្រួតពិនិត្យស្របទៅតាមស្តង់ដារអន្តរជាតិ៕

# IV- សកម្មភាពដទៃទៀតរបស់ ឯកឧត្តម ទេសរដ្ឋមន្ត្រី យឹម ណុលឡា ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែមីនា ឆ្នាំ២០១៧

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១ | **០២/០៣/១៧ ម៉ោង០៨:០០នាទី** | ចូលរួមជាកិត្តិយសក្នុងពិធីបើកជាផ្លូវការសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៧ លើប្រធានបទ "ការឈានឡើងក្នុងខ្សែចង្វាក់បង្កើតតម្លៃ សម្រាប់ ឧស្សាហូបនីយកម្មកំណើន និងការអភិវឌ្ឍក្នុងសម័យ ឌីជីថល" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារ សូហ្វីតែលភ្នំពេញ។ |
| ២ | **០២/០៣/១៧ ម៉ោង១៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីជប់លៀងដែលរៀបចំដោយ ធនាគារ ប្រេដ បែង (ខេមបូឌា) ភីអិលស៊ី នៅស្ថានទូតបារាំង។ |
| ៣ | **០៣/០៣/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់ជាតិចុះមូលដ្ឋានឃុំ០៦ នៃស្រុកព្រៃកប្បាស ខេត្តតាកែវ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ៤ | **០៦/០៣/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកការដ្ឋានសាងសង់ផ្លូវក្រវាត់ក្រុងទី២ កំណាត់ ទី២ ប្រវែង១៦,៧៩ គ.ម ពីទឹកថ្លា (មហាវិថីសហព័ន្ធរុស្ស៊ី) គ.ម ៩+៦២០ ភ្នំពេញ ទៅព្រែកហូរ (ផ្លូវជាតិលេខ២) គ.ម ២៦+៣១២ ក្រោមហិរញ្ញប្បទាន សម្បទានពីរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន និងសម្ពោធបើកឲ្យ ប្រើប្រាស់ជាផ្លូវការផ្លូវខ្សែក្រវាត់ក្រុងទី២ កំណាត់ទី១ ប្រវែង១០,២០៥ គ.ម ពីផ្លូវទំនប់កប់ស្រូវដល់ទឹកថ្លា (មហាវិថីសហព័ន្ធរុស្ស៊ី) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិព្រែកថ្លឹង សង្កាត់ ជើងឯក ខណ្ឌដង្កោ រាជធានីភ្នំពេញ។ |
| ៥ | **០៦/០៣/១៧ ម៉ោង១៨:០០នាទី** | ចូលរួមជាអធិបតី ក្នុងពិធីជូនភ្លើងបូជាសព ឯកឧត្តម **គឹម សយសាម៉ាឡៃន** អនុប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅវត្តពោធិព្រឹក្ស ហៅវត្តខ្វរ។ |
| ៦ | **០៧/០៣/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធគម្រោងពង្រីករោងចក្រផលិតស្រាបៀរកម្ពុជា ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅភូមិបោះអង្កាញ់ សង្កាត់ព្រែកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ |
| ៧ | **០៨/០៣/១៧ ម៉ោង០៨:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីអបអរសាទរខួបលើកទី១០៦ ទិវាអន្តរជាតិនារី ៨មីនា ២០១៧ ក្រោមប្រធានបទ "ស្ត្រីដើម្បីសុខសន្តិភាព និងវឌ្ឍនភាព" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ។ |
| ៨ | **១៣/០៣/១៧ ម៉ោង១៥:៣០នាទី** | ដឹកនាំកិច្ចប្រជុំគណៈកម្មការតាមដាន និងត្រួតពិនិត្យលើការសាងសង់អាកាសយានដ្ឋានអន្តរជាតិ ដើម្បីស្តាប់បទបង្ហាញពីក្រុមហ៊ុនសម្បទានអាកាសយានដ្ឋាន (SCA) ស្តីអំពីប្លង់ដំបូងស្លាកសញ្ញាបង្ហាញទិសចរាចរ នៃអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងអាកាសយានដ្ឋានអន្តរជាតិសៀមរាប (Concept Design Landside Signage for Phnom Penh and Siem Reap Airport) នៅទីស្តីការគណៈរដ្ឋមន្ត្រី ។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ៩ | **១៥/០៣/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធខ្សែកាប្លិ៍អុបទិកក្រោមបាតសមុទ្រ ម៉ាឡេស៊ី-កម្ពុជា-ថៃ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។ |
| ១០ | **១៥/០៣/១៧ ម៉ោង១៥:១៥នាទី** | ដឹកនាំកិច្ចប្រជុំក្រុមការងារថ្នាក់កណ្តាលចុះជួយឃុំ០៦ ដើម្បីស្តាប់របាយការណ៍ ស្តីពីការអនុវត្តការងារកន្លងមក និងផែនការបន្តរបស់គណបក្ស ស្រុកព្រៃកប្បាស ខេត្តតាកែវ ដែលធ្វើបទបង្ហាញដោយលោក **ឈាវ ហ៊** នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ១១ | **១៨/០៣/១៧ ម៉ោង០៨:៣០នាទី** | ដឹកនាំគណៈប្រតិភូរបស់ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ចូលរួមគោរពវិញ្ញាណក្ខន្ធ សម្តេចវិបុលបញ្ញា **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅភូមិគ្រឹះនៃសព។ |
| ១២ | **១៩/០៣/១៧ ម៉ោង០៧:០០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីដង្ហែរសព សម្តេចវិបុលបញ្ញា **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី នៅភូមិគ្រឹះនៃសព។ |
| ១៣ | **២១/០៣/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីបើកសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៥-២០១៦ និងលើកទិសដៅឆ្នាំសិក្សា២០១៦-២០១៧ ក្រោមអធិបតីភាព លោកជំទាវ **ម៉ែន សំអន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ១៤ | **២២/០៣/១៧ ម៉ោង០៧:៣០នាទី** | ចូលរួមជាកិត្តិយស ក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ មជ្ឈមណ្ឌលហ្វឹកហ្វឺនអាកាសចរស៊ីវិល ក្រោមអធិបតីភាព ឯកឧត្តម **ទៀ បាញ់** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ តំណាងដ៏ខ្ពង់ខ្ពស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។ |
| ១៥ | **២២/០៣/១៧ ម៉ោង១៤:០០នាទី** | ចូលរួមកិច្ចប្រជុំ ប្រកាសប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចវិបុលសេនាភក្តី **សាយ ឈុំ** អនុប្រធានគណបក្សប្រជាជនកម្ពុជា និងជាប្រធានគណៈប្រចាំការគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ១៦ | **២៣/០៣/១៧ ម៉ោង០៩:៣០នាទី** | ដឹកនាំអង្គប្រជុំ ដើម្បីពិនិត្យ និងពិភាក្សាលើ៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីឧបាស្រ័យពាណិជ្ជកម្ម។<br>២-សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។<br>៣-បញ្ហាផ្សេងៗ។<br>ដើម្បីត្រៀមប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |

| ល.រ | កាលបរិច្ឆេទ | សកម្មភាព |
|---|---|---|
| ១៧ | ២៣/០៣/១៧ ម៉ោង១៤:៣០នាទី | ចូលរួមជាកិត្តិយស ក្នុងពិធីបិទសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០១៥-២០១៦ និងលើកទិសដៅឆ្នាំសិក្សា២០១៦-២០១៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និង**សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា។ |
| ១៨ | ២៤/០៣/១៧ ម៉ោង០៨:៣០នាទី | ចូលរួមក្នុងអង្គប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាលើរបៀបវារៈដូចខាងក្រោម៖<br>១-សេចក្តីព្រាងច្បាប់ ស្តីពីឧបាស្រ័យពាណិជ្ជកម្ម។<br>២-សេចក្តីព្រាងក្របខ័ណ្ឌគោលនយោបាយជាតិគាំពារសង្គម ២០១៦-២០២៥។<br>៣-បញ្ហាផ្សេងៗ។ នៅទីស្តីការនាយករដ្ឋមន្ត្រី។ |
| ១៩ | ២៧/០៣/១៧ ម៉ោង១០:៣០នាទី | ជួបប្រជុំពិភាក្សាការងារជាមួយ ឯកឧត្តម **ផែន សុទិដ្ឋារ៉េនោ** នៅបន្ទប់ឯកឧត្តមប្រធាន (ECOSOCC) នៃទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២០ | ២៧/០៣/១៧ ម៉ោង១៥:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិនៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២១ | ២៨/០៣/១៧ ម៉ោង០៨:៣០នាទី | ដឹកនាំកិច្ចប្រជុំក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ដើម្បីប្រជុំស្តីពីការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ប្រចាំខែកុម្ភៈ ឆ្នាំ២០១៧ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២២ | ២៨/០៣/១៧ ម៉ោង១៥:១៥នាទី | បន្តដឹកនាំកិច្ចប្រជុំគណៈកម្មាធិការប្រតិបត្តិ នៃក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៣ | ៣០/០៣/១៧ ម៉ោង០៩:៣០នាទី | ដឹកនាំកិច្ចប្រជុំគណៈកម្មការត្រួតពិនិត្យ និងវាយតម្លៃស្ថានភាពហិរញ្ញវត្ថុ និងទុនវិនិយោគ របស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ (SCA) និងគណៈកម្មាការចចារជាមួយក្រុមហ៊ុនសម្បទានព្រលានយន្តហោះ(SCA) ដើម្បីទូទាត់សំណងសម្រាប់ការបញ្ចប់កិច្ចសន្យាសម្បទានមុនពេលកំណត់ នៅទីស្តីការគណៈរដ្ឋមន្ត្រី។ |
| ២៤ | ៣០/០៣/១៧ ម៉ោង១៤:៣០នាទី | ចូលរួមកិច្ចប្រជុំពិសេសរបស់ក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ ក្រោមអធិបតីភាព ឯកឧត្តម នាយឧត្តមសេនីយ៍ **ប៉ុល សារឿន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅមន្ទីរគណៈកម្មាធិការគណបក្សខេត្តតាកែវ។ |
| ២៥ | ៣១/០៣/១៧ ម៉ោង០៨:០០នាទី | ចូលរួមកិត្តិយស ក្នុងពិធីជួបសំណេះសំណាលជាមួយបេក្ខជនក្រុមប្រឹក្សាឃុំអាណត្តិទី៤ ទាំងពេញសិទ្ធិ ត្រៀម និងបម្រុង ក្រោមអធិបតីភាព ឯកឧត្តមនាយឧត្តមសេនីយ៍ **ប៉ុល សារឿន** សមាជិកគណៈអចិន្ត្រៃយ៍គណៈកម្មាធិការកណ្តាលគណបក្សប្រជាជនកម្ពុជា និងជាប្រធានក្រុមការងារថ្នាក់កណ្តាលចុះជួយខេត្តតាកែវ នៅស្នាក់ការសហភាពសហព័ន្ធយុវជនស្រុកព្រៃកប្បាស។ |

# ព្រឹត្តិបត្រព័ត៌មាន



## ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌


ទូរស័ព្ទលេខ: ០២៣ ២១១ ៩៤៣ ០១៦ ៣០៧ ៣៣០

ទូរសារលេខ: ០២៣ ២១១ ៩៤៣

E-mail: veasna@live.in